ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងរដ្ឋប្បវេណីលេខ៖ ៩០៧ ចុះថ្ងៃទី ២៥.តុលា.២០១៩
សញ្ញាណរឿងក្ដី៖ ប្ដឹងសុំលែងលះប្រពន្ធ
សាលក្រមលេខ៖ ០២៧ (ណ)
ប្រកាសសាលក្រមថ្ងៃទី ០៧ -មេសា -២០២០

## តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្ដាល បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ជាសាធារណៈ នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០២០ ។

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

### ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted] ក្រឡាបញ្ជី

សាលាដំបូងខេត្តកណ្ដាល បានចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម:

-ដើមចោទ៖ឈ្មោះ [redacted] សំណាង ភេទ ប្រុស អាយុ ៤០ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅ ភូមិ [redacted] ។

-មេធាវីតំណាងដោយអាណត្តិ: កញ្ញា [redacted] ស្រីអូន អត្តលេខ ១៤១៥T និង លោក [redacted] កែវសុត្ថា អត្តលេខ ៤៨៥ មានការិយាល័យក្រុមមេធាវី [redacted] អាសយដ្ឋាន ផ្ទះ [redacted] ។

-ចុងចម្លើយ៖ឈ្មោះ [redacted] សុគន្ធា ភេទ ស្រី អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅ ភូមិ [redacted]។

-មេធាវីតំណាងដោយអាណត្តិ: លោកស្រី [redacted]ជាមេធាវី អត្តលេខ ៩៨៨ ជាសមាជិកគណៈមេធាវី ការិយាល័យ [redacted] ។

កម្មវត្ថុ:១.ប្ដឹងសុំលែងលះពីប្រពន្ធឈ្មោះ [redacted] សុគន្ធា

២.ឱ្យឈ្មោះ [redacted] សុគន្ធា ជាអ្នកមានអំណាចលើកូនទាំងពីរឈ្មោះ [redacted] មរកត ភេទ ស្រី ថ្ងៃខែឆ្នាំកំណើត ១៦-០១-២០០១ និង ឈ្មោះ [redacted] គុជរាជសិទ្ធ ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត ២២-០១-២០១១។

៣.សុំផ្ដល់អាហារកាតព្វកិច្ចចិញ្ចឹមកូន ឈ្មោះ [redacted] គុជរាជសិទ្ធិ ក្នុងមួយខែ ៣០០ ០០០ (បីរយពាន់)រៀល ក្នុងមួយខែ។

៤.សុំបែងចែកទ្រព្យរួម:ផ្ទះ និង ដី ០១ កន្លែងទំហំ ៨៥៥ ម$^2$ (ប្រាំបីរយហាសិបប្រាំម៉ែត្រការ៉េ) មានទីតាំងស្ថិតនៅភូមិ ប្របវត្ត ឃុំ ព្រៃពួច ស្រុក អង្គស្នួល ខេត្ត កណ្ដាល

(កិច្ចសន្យាលក់ដី និង ផ្ទេរសិទ្ធិកាន់កាប់លេខ ៣៩៥/១៣ ពព ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៣ ចុះហត្ថលេខាដោយលោក ទូច ផុន មេឃុំព្រៃពួច)។

## អង្គហេតុ និងចំណុចវិវាទ

១. ការពន្យល់ត្រួសៗអំពីរឿងក្តី

ដើមចោទឈ្មោះ [redacted] សំណាង និងចុងចម្លើយឈ្មោះ [redacted] សុគន្ធា បានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នៅឆ្នាំ២០០០។ ក្នុងអំឡុងពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធមានកូន២នាក់ កូនទី១ឈ្មោះ [redacted] មរកត ភេទ ស្រី ថ្ងៃខែឆ្នាំកំណើត ១៦-០១-២០០១ (ដល់នីតិភាព) និង កូនទី២ ឈ្មោះ [redacted] គុជរាជសិទ្ធ ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត ២២-០១-២០១១។ ទ្រព្យសម្បត្តិរួមមាន ផ្ទះ និង ដី ១កន្លែងទំហំ ៨៥៥ ម$^2$ (ប្រាំបីរយហាសិបប្រាំម៉ែត្រការ៉េ) ស្ថិតនៅភូមិ ប្របវត្ត ឃុំ ព្រៃពួច ស្រុក អង្គស្នួល ខេត្ត កណ្តាល និង មានបំណុលរួម ២១ ០០០ (ពីរម៉ឺនមួយពាន់) ដុល្លារអាមេរិក។ ក្នុងការរស់នៅជាមួយគ្នាប៉ុន្មានឆ្នាំចុងក្រោយ តែងមានភាពរកាំរកូស និង ទំនាស់ពាក្យសម្តីនឹងគ្នាជាញឹកញាប់ ជាហេតុនាំ អោយដើមចោទអស់មនោសញ្ចេតនា ជាមួយចុងចម្លើយ ទើបដើមចោទដាក់ពាក្យបណ្តឹង លែងលះជាមួយចុងចម្លើយ។

២.អង្គហេតុដែលជាមូលហេតុនៃការទាមទារ

មូលហេតុដែលដើមចោទឈ្មោះ [redacted] សំណាង ប្តឹងសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] សុគន្ធា ដោយសារដើមចោទ និង ចុងចម្លើយ តែងតែមានភាពរកាំរកូស និង ទំនាស់ពាក្យសម្តីនឹងគ្នាជាញឹកញាប់ ទន្ទឹមនឹងនេះចុងចម្លើយតែងជេរប្រមាថ និង មាកងាយដល់ដើមចោទដែលជាហេតុនាំអោយដើមចោទអស់មនោសញ្ចេតនាជាមួយចុងចម្លើយ។

៣.សាលក្រមដែលទាមទារដោយដើមចោទ

៣.១.ប្តឹងសុំលែងលះពីប្រពន្ធឈ្មោះ [redacted] សុគន្ធា

៣.២.ឱ្យឈ្មោះ [redacted] សុគន្ធា ជាអ្នកមានអំណាចលើកូនទាំងពីរឈ្មោះ [redacted] មរកត ភេទស្រី ថ្ងៃខែឆ្នាំកំណើត ១៦-០១-២០០១ និង ឈ្មោះ [redacted] គុជរាជសិទ្ធ ភេទ ប្រុសថ្ងៃខែឆ្នាំកំណើត ២២-០១-២០១១។

៣.៣.សុំផ្តល់អាហារកាតព្វកិច្ចចិញ្ចឹមកូនឈ្មោះ [redacted] គុជរាជសិទ្ធិ ក្នុងមួយ ខែ ចំនួន ៣០០ ០០០ (បីរយពាន់) រៀល ក្នុងមួយខែ។

៣.៤.សុំបែងចែកទ្រព្យរួម: ផ្ទះ និង ដី ០១កន្លែងទំហំ ៨៥៥ ម$^2$(ប្រាំបីរយហាសិបប្រាំម៉ែត្រការ៉េ) មានទីតាំងស្ថិតនៅភូមិ ប្របវត្ត ឃុំ ព្រៃពួច ស្រុក អង្គស្នួល ខេត្ត កណ្តាល (កិច្ចសន្យាលក់ដី និង ផ្ទេរសិទ្ធិកាន់កាប់លេខ ៣៩៥/១៣ ពព ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៣ ចុះហត្ថលេខាដោយលោក ទូច ផុន មេឃុំព្រៃពួច)។

៤.មេធាវីតំណាងដោយអាណត្តិថ្លែងការណ៍ថា: សុំឱ្យតុលាការសម្រេច

-ប្តឹងសុំលែងលះពីប្រពន្ធឈ្មោះ [redacted] សុគន្ធា

-ឱ្យឈ្មោះ [redacted] សុគន្ធា ជាអ្នកមានអំណាចលើកូនទាំងពីរឈ្មោះ [redacted] មរកត ភេទស្រី ថ្ងៃខែឆ្នាំកំណើត ១៦-០១-២០០១ និង ឈ្មោះ [redacted] គុជរាជសិទ្ធ ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត ២២-០១-២០១១។

-សុំផ្តល់អាហារកាតព្វកិច្ចចិញ្ចឹមកូន ឈ្មោះ [redacted] គុជរាជសិទ្ធិ ក្នុងមួយខែ ៣០០ ០០០ (បីរយពាន់)រៀល ក្នុងមួយខែ។

-សុំបែងចែកទ្រព្យរួម: ផ្ទះ និង ដី ០១ កន្លែងទំហំ ៨៥៥ ម$^2$ (ប្រាំបីរយហាសិបប្រាំម៉ែត្រការ៉េ) មានទីតាំងស្ថិតនៅភូមិ ប្របវត្ត ឃុំ ព្រៃពួច ស្រុក អង្គស្នួល ខេត្ត កណ្តាល (កិច្ចសន្យា

លក់ដី និង ផ្ទេរសិទ្ធិកាន់កាប់លេខ ៣៩៥/១៣ ពព ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៣ ចុះហត្ថលេខាដោយលោក ទូច ផុន មេឃុំព្រៃពួច)។ ដោយមានអង្គហេតុចាំបាច់: កូនក្តីរបស់ខ្លួន មានសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ជាមួយចុងចម្លើយ សំបុត្រលេខ ០២ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០០។ មានកូនពីរនាក់នាក់ កូនទី១ឈ្មោះ [redacted] មរកត ភេទ ស្រី ថ្ងៃខែឆ្នាំកំណើត ១៦-០១-២០០១ និង កូនទី២ ឈ្មោះ [redacted] គុជរាជសិទ្ធ ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត ២២-០១-២០១១។ ក្នុងចំណងអាពាហ៍ពិពាហ៍មានទ្រព្យរួម ផ្ទះ និង ដី ០១ កន្លែងទំហំ ៨៥៥ម$^{2}$ (ប្រាំបីរយហាសិបប្រាំម៉ែត្រការ៉េ) មានទីតាំងស្ថិតនៅភូមិ ប្របវត្ត ឃុំ ព្រៃពួច ស្រុក អង្គស្នួល ខេត្តកណ្តាល។

៥.ការអះអាងរបស់ដើមចោទ៖ ខ្លួនជាប៉ូលីសសន្តិសុខ មានប្រាក់ខែ ៨០០ ០០០ (ប៉ែតសិបម៉ឺន) រៀល និង ប្រាក់ចំណូល ២៥០ (ពីររយហាសិប) ដុល្លារអាមេរិក។ ក្នុងការខ្ចីលុយធនាគារគឺខ្លួន បានអោយលុយទៅប្រពន្ធក្នុង ១ខែ ២៥០ (ពីររយហាសិប) ដុល្លារអាមេរិក ដើម្បីបង់ធនាគារ។ ក្នុងឆ្នាំ ២០០៧ ខ្លួនជាអ្នកលក់ទូរស័ព្ទជាមួយគាត់ ខ្លួនបានដឹងថាអ៊ុំចង់លក់ដី ខ្លួនក៏បានពិភាក្សាគ្នា ជាមួយ ដើម្បីទិញដីនោះ។

៦.ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយ: ថ្លែងការណ៍ថា កូនក្តីរបស់ខ្លួនឯកភាពលើការលែងលះ និង សិទ្ធិគ្រប់គ្រងកូន តែពុំឯកភាពលើចំណុច អាហារកាត្តកិច្ចចិញ្ចឹមកូន ៣០០ ០០០ (សាមសិបម៉ឺន) រៀល នោះទេ គឺកូនក្តីរបស់ខ្លួនសុំផ្តាច់ ២០ ០០០ (ពីរម៉ឺនដុល្លារ) អាមេរិក។ មិនឯកភាពទ្រព្យរួម និង បំណុល នោះទេ ដោយហេតុថា ទ្រព្យនោះជាដីរបស់កូនក្តីរបស់ខ្លួនតែម្នាក់ឯង ហើយដើម្បីខ្ចីលុយធ្វើផ្ទះបាន គឺទាមទារដាក់ទ្រព្យប្តីប្រពន្ធ ទើបអាចខ្ចីលុយបាន។

៧.ការអះអាងរបស់ចុងចម្លើយ៖ ដីនេះគឺប៉ារបស់ខ្លួនជាអ្នកទិញអោយខ្លួន នៅឆ្នាំ ២០០៧ ពីអ៊ុំរបស់ខ្លួនគាត់បានដាក់ឈ្មោះខ្លួន ([redacted] សុភា) ដោយសារតែគាត់គិតថា ខ្លួន និង ប្តីលែលះហើយដោយ នៅពេលនោះពុំមានប្តីរបស់ខ្លួននោះទេ។ តែក្រោយមកមានបំណងចង់ធ្វើផ្ទះ ទើបដាក់ជាទ្រព្យប្តី ប្រពន្ធដើម្បីខ្ចីលុយធនាគារ ដែលពុំបានខ្ចីនោះទេ គឺខ្លួនមានលុយខ្លះ និង លុយឪពុកក្មេកខ្លះ បានសាងសង់ផ្ទះហើយ ហើយឪពុកក្មេករបស់ខ្លួនបានឱ្យផ្ទះនេះ ទៅកូនៗរបស់ខ្លួន។ នៅពេលទិញដីនោះ ខ្លួនមានប្តីហើយ តែពុំមានសំបុត្រលែងលះនោះទេ។ នៅឆ្នាំ២០១៣ ខ្លួនបានសុំ ប៉ាដាក់ផ្ទេរឈ្មោះ ប្តីប្រពន្ធដើម្បីខ្ចីលុយ ដើម្បីធ្វើផ្ទះតែពុំបានខ្ចីទេ ដោយឪពុកក្មេក និងប៉ារបស់ខ្លួនជួយ។ ខ្លួនមិនបានប្តឹងរំលាយវិមោឃ:ភាព ដើម្បីរំលាយប្លង់កម្មសិទ្ធិនោះទេ គឺខ្លួនទុក ដើម្បីពេលចាំបាច់។

៨.ការអះអាងរបស់សាក្សី

៨.១.សាក្សីឈ្មោះ [redacted] ទង ថ្លែងការណ៍៖ ខ្លួនជាអាចារ្យវត្ត និង ជាជាងធ្វើផ្ទះរបស់ឈ្មោះ [redacted] សំណាង។ ការទិញសម្ភារ:ដែលធ្វើផ្ទះ គឺម្តាយរបស់ដើមចោទ ជាអ្នកអោយលុយទៅទិញ។ ខ្លួន ជាជាងសាងសង់ផ្ទះតែកម្លាំងពលកម្ម និង ថ្លៃជាងប៉ុនណ្ណោះ ក្នុងតម្លៃ ៣៦០០ (បីពាន់ប្រាំមួយរយ) ដុល្លារអាមេរិក។ ចំពោះសម្ភារ: គឺពេលខ្លះគឺម្តាយរបស់ដើមចោទ ទៅទិញ ដែលសរុបថ្លៃផ្ទះ ៣០ ០០០ (បីម៉ឺន) ដុល្លារអាមេរិក។ ចំពោះលោកស្រី ផល សុគន្ធា គាត់មិនដែលឱ្យលុយទៅទិញ នោះ ទេ។

៨.២.សាក្សីឈ្មោះ [redacted] ចាន់ថេង ថ្លែងការណ៍៖ ខ្លួនជាអ្នករៀបចំក្រុងពាលីសាងសង់ផ្ទះ។ ខ្លួនដឹងថាផ្ទះចំណាយលុយប្រហែល ៣០ ០០០ (បីម៉ឺន) ដុល្លារអាមេរិក តាមរយ:ប្តីរបស់ខ្លួនជាជាងធ្វើផ្ទះ។

៨.៣.សាក្សីឈ្មោះ [redacted] សុភារម្យ ថ្លែងការណ៍៖ ខ្លួនជាជាងសាងសង់របស់ដើមចោទ ដោយថ្លៃឈ្នួល ៣៦០០ (បីពាន់ប្រាំមួយរយ) ដុល្លារអាមេរិក។ ពេលខ្លួនបើកលុយគឺខ្លួនបើកពី ឪពុកម្តាយរបស់គាត់។ ខ្លួនមិនដែលទទួលលុយពីប្រពន្ធរបស់លោក សំណាងនោះទេ។ ផ្ទះនោះទំហំ ៧ គុណ ១១ម៉ែត្រ ដែលមានជាងធ្វើផ្ទះ ៥នាក់។

៨.៤.សាក្សីឈ្មោះ [redacted] ហុងលី ថ្លែងការណ៍៖ ខ្លួនបានលក់ដីរបស់ខ្លួន អោយទៅប្អូន របស់ខ្លួន ជាដីគេហដ្ឋាន ក្នុងតម្លៃ ៦ ០០០ (ប្រាំមួយពាន់) ដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៧ មានលិខិតត្រឹមភូមិ ដាក់ឈ្មោះអ្នកទិញឈ្មោះ [redacted] ផល និង [redacted] សុជា។ ក្រោយមកឆ្នាំ ២០១៣ គេបានធ្វើលិខិតផ្ទេរសិទ្ធិ ទៅឈ្មោះ [redacted] សុគន្ធា និង [redacted] សំណាងវិញ ដើម្បីធ្វើប័ណ្ណកម្មសិទ្ធិ ពីរនាក់ប្តីប្រពន្ធដើម្បីខ្ចីលុយធនាគារ។ លុយថ្លៃដីគឺប្អូនរបស់ខ្លួនជាអ្នកឱ្យ មិនដឹងថាជាលុយអ្នកណានោះទេ។

៨.៥.សាក្សីឈ្មោះ [redacted] ផលថ្លែងការណ៍ថា៖ នៅឆ្នាំ២០០៧ ខ្លួនបានទិញដីពីបងប្រុស ខ្លួនដើម្បីឱ្យកូនរបស់ខ្លួនឈ្មោះ [redacted] សុគន្ធា ក្នុងតម្លៃ ៦ ០០០ (ប្រាំមួយពាន់) ដុល្លារអាមេរិក ដោយលុយជាលុយរបស់ខ្លួន។ ពេលនោះកូនប្រសាររបស់ខ្លួនពុំបានរស់នៅទេ។ ចំពោះការសាងសង់ផ្ទះគឺខ្លួនបានចូលរួម៣ ០០០ (បីពាន់)ដុល្លារអាមេរិក។ ចំពោះការផ្ទេរសិទ្ធិឱ្យកូន និង កូនប្រសារនៅឆ្នាំ ២០១៣ គឺដើម្បីខ្ចីលុយធនាគារ។ នៅឆ្នាំ ២០១៧ គឺបានខ្ចីលុយធនាគារ។

៨.៦.សាក្សីឈ្មោះ [redacted] ណារឿន ថ្លែងការណថា: ខ្លួនជាបងជីដូនមួយ ចុងចម្លើយ មានផ្ទះជាប់គ្នា ខ្លួនដឹងថាដីនេះទិញពីឈ្មោះ [redacted] ហុងលី ដាក់ឈ្មោះ [redacted] សុគន្ធា ហើយក្រោយមកដាក់ឈ្មោះ ប្តីប្រពន្ធដើម្បីខ្ចីលុយធនាគារ។ នៅពេលទិញដីឈ្មោះ [redacted] សំណាងពុំបាននៅទេ ។ ក្នុងការផ្ទេរសិទ្ធិ គឺខ្លួនជាអ្នកផ្តិតមេដៃធ្វើសាក្សី។ ចំពោះការសង់ផ្ទះខ្លួនពុំដឹងថាអស់ប៉ុន្មាននោះទេ។

៨.៧.សាក្សីឈ្មោះ [redacted] អ៊ីន ថ្លែងការណ៍ថា៖ ខ្លួនរស់នៅភូមិជាមួយចុងចម្លើយ។ ខ្លួនដឹងថាដំបូងឡើយ ឈ្មោះ ហុងលី លក់ដីអោយ [redacted] សុគន្ធា។ គាត់ទាំងពីរនៅពេលឈ្លោះគ្នា បានចូលមកឃុំអោយជួយដោះស្រាយ ។ កាលពេលនោះឃុំ បានព្រមព្រៀងចែកដីនោះជាពីរ តែក្រោយមកគាត់មិនព្រមនោះទេ។ នៅសាលាឃុំគាត់ទាំងពីរ បានអោយខ្លួនធ្វើកំណត់ហេតុបែងចែកទ្រព្យសម្បត្តិមានដី និង ផ្ទះ ។ ចំពោះបំណុលមានជំពាក់ឈ្មោះ [redacted] សុជា ។

៨.៨.សាក្សីឈ្មោះ [redacted] សុធារ៉ា ថ្លែងការណ៖ ខ្លួនត្រូវជាប្អូនបង្កើតរបស់ចុងចម្លើយ។ ពីដើមមកបងថ្លៃពុំបានរស់នៅនោះទេ។ នៅឆ្នាំ២០០៧ ប៉ារបស់ខ្លួន បានទិញដីឱ្យបងស្រីរបស់ខ្លួន ក្រោយមកបងថ្លៃ បានត្រឡប់មកវិញជួបជុំគ្រួសារ ហើយក៏បានរៀបចំធ្វើផ្ទះ ក៏បានដាក់ឈ្មោះ ពីរនាក់ប្តីប្រពន្ធ ដើម្បីខ្ចីប្រាក់ពីធនាគារ។ ដីនោះអ៊ុំរបស់ខ្លួន បានលក់ឱ្យឪពុកម្តាយរបស់ខ្លួនដើម្បីប្រគល់អោយបងស្រី [redacted] សុគន្ធា។

៩.ការពិនិត្យភស្តុតាងជាឯកសារ:

៩.១.ភស្តុតាងជាឯកសាររបស់ចុងចម្លើយ

-លិខិតបញ្ជាក់អំពីប្រវត្តិដី ចុះថ្ងៃទី ២០-វិច្ឆិកា-២០១៩ របស់ឈ្មោះ [redacted] ហុងលី ហៅ [redacted] ស៊ីថេន និង ប្រពន្ធឈ្មោះ [redacted] គា។

-លិខិតបញ្ជាក់អំពីប្រវត្តិដី និង ផ្ទះចុះថ្ងៃទី២០-វិច្ឆិកា-២០១៩ របស់ឈ្មោះ [redacted] ផល និង ប្រពន្ធឈ្មោះ [redacted] គា ហៅ [redacted] គីម។

-លិខិតបញ្ជាក់អំពីប្រវត្តិដី ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០១៩របស់មេឃុំព្រៃពួច ឈ្មោះ [redacted] ផុន។

-កិច្ចសន្យាលក់ដីចុះថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ រវាងឈ្មោះ [redacted] ហុងលី និង ប្រពន្ធឈ្មោះ [redacted] គា ជាមួយឈ្មោះ [redacted] សុភា ដោយមានាការដឹងលឺពីមេភូមិ ប្របវត្ត [redacted] ឡេងឈាង។



Scanned with CamScanner

-កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៩ រវាងឈ្មោះ [redacted] សុគន្ធា និង ឈ្មោះ [redacted] ថារី។

-កាលវិភាគសងប្រាក់ ចុះថ្ងៃទី២៨ ខែ មេសា ឆ្នាំ ២០១៧ រវាងឈ្មោះ [redacted] សុគន្ធា និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់លើទី១។

-កាលវិភាគសងប្រាក់ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៧ រវាងឈ្មោះ [redacted] សុគន្ធា និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ លើទី២ ខ្ចីអោយឈ្មោះ [redacted] សំណាង បានយកទៅអោយឈ្មោះ [redacted] ផល្លី។

-កំណត់ហេតុប្រគល់ និង ទទួល ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៩ របស់អធិការដ្ឋាន ស្រុក អង្គស្នួល។

៩.២.ភស្តុតាងជាឯកសាររបស់ចុងចម្លើយៈ

-លិខិតបញ្ជាក់ពីលោកមេឃុំ ព្រៃពួច ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ។

**១០.ចំណុចវិវាទ និង ចំណុចគ្មានវិវាទ**

**១០.១.ចំណុចវិវាទ**

-មិនឯកភាពលើការបែងចែកទ្រព្យសម្បត្តិរួម

-មិនឯកភាពលើការបែងចែកបំណុល

-អាហារការគតព្វកិច្ចចិញ្ចឹមកូន

**១០.២.ចំណុចគ្មានវិវាទ**

-ការលែងលះ

-សិទ្ធិអំណាចមេបា

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ដើមចោទ

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ

ក្រោយពីថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

ក្រោយពីបានធ្វើការសាកសួរភាគីដើមចោទ ធ្វើការផ្សះផ្សា និងធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ តុលាការយល់ឃើញថាៈ

១.គូភាគីពិតជាបានរួមរស់ជាមួយគ្នាជាប្តីប្រពន្ធតាមច្បាប់ដោយ មានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ០២ ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២ ០០០ ពិតប្រាកដមែន។

២.ក្នុងអំឡុងពេលរស់នៅជាមួយគ្នាមានកូន ២នាក់ កូនទី១ ឈ្មោះ [redacted] មរកត ភេទ ស្រី ថ្ងៃខែឆ្នាំកំណើត ១៦-០១-២០០១ និង កូនទី២ ឈ្មោះ [redacted] គុជរាជសិទ្ធ ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត ២២-០១-២០១១។ ទ្រព្យសម្បត្តិរួមមានផ្ទះ និង ដី ១កន្លែងទំហំ ៨៥៥ ម² (ប្រាំបីរយហាសិបប្រាំម៉ែត្រ) ការ៉េ ស្ថិតនៅភូមិ ប្របវត្ត ឃុំ ព្រៃពួច ស្រុក អង្គស្នួល ខេត្ត កណ្តាល និង មានបំណុលរួម ២១ ០០០ (ពីរម៉ឺនមួយពាន់) ដុល្លារអាមេរិក។ ក្នុងការរស់នៅជាមួយគ្នាប៉ុន្មានឆ្នាំចុងក្រោយ តែងមានភាពរកាំរកូស និងទំនាស់ពាក្យសម្តីនឹងគ្នាជាញឹកញាប់ ជាហេតុនាំអោយ ដើមចោទអស់មនោសញ្ចេតនាជាមួយចុងចម្លើយ ទើបដើមចោទដាក់ពាក្យបណ្តឹងលែងលះជាមួយចុងចម្លើយ។

៣-ភាគីដើមចោទ និង ចុងចម្លើយបានឯកភាពលើការលែងលះ និង សិទ្ធិអំណាចមេបាលើកូន តែពុំឯកភាពលើការបែងចែកទ្រព្យសម្បត្តិ និង បែកចែកបំណុលនោះទេ។ ដោយភាគីខាងដើមចោទបានដាក់ភស្តុតាង និងសាក្សី អំពីផ្ទះ និង ដី១កន្លែងទំហំ ៨៥៥ ម² (ប្រាំបីរយហា

សិបប្រាំម៉ែត្រ) ការ៉េ ស្ថិតនៅភូមិ ប្របវត្ត ឃុំ ព្រៃពូច ស្រុក អង្គស្នួល ខេត្ត កណ្តាល ជាទ្រព្យសម្បត្តិរួម ចំណែកចុងចម្លើយបានដាក់ភស្តុតាង និង សាក្សី ដើម្បីបញ្ជាក់ថាជាទ្រព្យដោយឡែក។

៤.តាមកិច្ចសន្យាលក់ដី និង ផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី ៩ ខែ ១០ ឆ្នាំ ២០១៣ បញ្ជាក់បានថា ឈ្មោះ [redacted] ស៊ីថេន បានលក់ដីមួយកន្លែងទំហំ ៨៥៥ ម៉ែត្រការ៉េ មានព្រំប្រទល់ ខាងជើងទល់នឹង [redacted] បាន ,ខាងត្បូងទល់នឹង [redacted] ខែម,ខាងកើតទល់នឹងផ្លូវលំ និង ខាងលិចទល់នឹង ស្រែ [redacted] សុន ស្ថិតនៅភូមិ ប្របវត្ត ឃុំ ព្រៃពូច ស្រុក អង្គស្នួល ខេត្ត កណ្តាល អោយទៅឈ្មោះ [redacted] សំណាង និង ប្រពន្ធឈ្មោះ [redacted] សុគន្ធា។

៥.តាមការអះអាងរបស់ចុងចម្លើយ និង សាក្សីឈ្មោះ [redacted] ផល,ឈ្មោះ [redacted] ណារឿន ,ឈ្មោះ [redacted] សុផារ៉ា ថាការដាក់ឈ្មោះ ប្តីប្រពន្ធនៅក្នុងកិច្ចសន្យាលក់ដី និង ផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី ៩ ខែ ១០ ឆ្នាំ ២០១៣ ដើម្បីខ្ចីលុយពីធនាគារ ពុំមែនជាទ្រព្យសម្បត្តិរួមនោះទេ គឺជាទ្រព្យរបស់ឈ្មោះ [redacted] សុគន្ធា ម្នាក់តែប៉ុណ្ណោះ។ ការអះអាងនេះពុំមែនជាអង្គហេតុគតិយុត្តដែលអាចកំណត់ថាជាទ្រព្យដោយឡែកនោះទេ គប្បីតុលាការជឿជាក់លើឯកសារគតិយុត្តិគឺកិច្ចសន្យាលក់ដី និង ផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី ៩ ខែ ១០ ឆ្នាំ ២០១៣ ដែលមានឈ្មោះ [redacted] សុគន្ធា និង ប៊ុន សំណាង ជាម្ចាស់សិទ្ធិកាន់កាប់ និង ជាទ្រព្យសម្បត្តិរួម។

៦.ក្នុងពេលលែងលះគ្នានេះ ដើមចោទ និង ចុងចម្លើយ បានយល់ព្រមចំពោះអំណាចមេបាលើកូនឱ្យទៅចុងចម្លើយគប្បីតុលាការសម្រេចតាមការព្រមព្រៀង។

៧.ភាគីដើមចោទ និង ចុងចម្លើយ ពុំបានដាក់ភស្តុតាងពី បំណុល ២១០០០ (ពីរម៉ឺនមួយពាន់) ដុល្លារអាមេរិក ដែលជំពាក់ម្តាយចុងចម្លើយ ៦០០០ (ប្រាំមួយពាន់) ដុល្លារអាមេរិក និងម្តាយដើមចោទ ១៥ ០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក នោះទេគប្បីតុលាការពុំអាចសម្រេចបានឡើយ ។

៨.តាមមាត្រា ៩៩០ ក្រមរដ្ឋប្បវេណី កថាខណ្ឌទី២.ក្នុងករណីមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធបានទេ ត្រូវបែងចែកទ្រព្យសម្បត្តិដោយផ្អែកតាម ក.[......] ខ.បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែកសហព័ទ្ធនីមួយៗ មានសិទ្ធិទទួលយក ១ភាគ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរួម។

៩. រឿងក្តីនេះតុលាការអស់លទ្ធភាពក្នុងការផ្សះផ្សាហើយ ។

១០.ផ្អែកតាមសំអាងហេតុខាងលើនេះ ការទាមទាររបស់ដើមចោទមានមូលដ្ឋានសំអាងត្រឹមត្រូវតាមច្បាប់ គប្បីតុលាការទទួលស្គាល់នូវការទាមទារនេះ ។

១១.ប្រាក់ប្រដាប់ក្តីអនុលោមតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី កំណត់ឲ្យចុងចម្លើយទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ។

## សេចក្តីសម្រេចបញ្ចប់

១-ឲ្យដើមចោទឈ្មោះ [redacted] សំណាង លែងលះពីចុងចម្លើយឈ្មោះ [redacted] សុគន្ធា គិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ។

២-បែកចែកជា ២ចំណែកស្មើគ្នាដោយគិតជាតម្លៃ នូវទ្រព្យសម្បត្តិរួមអោយទៅដើមចោទឈ្មោះ [redacted] សំណាង និង ឈ្មោះ [redacted] សុគន្ធា នូវ ផ្ទះនិង ដី ០១ កន្លែងទំហំ ៨៥៥ ម$^2$( ប្រាំបីរយហាសិបប្រាំម៉ែត្រ ការ៉េ) មានទីតាំងស្ថិតនៅភូមិ ប្របវត្ត ឃុំ ព្រៃពូច ស្រុក អង្គស្នួល ខេត្ត កណ្តាល (កិច្ចសន្យាលក់ ដី និង ផ្ទេរសិទ្ធិកាន់កាប់លេខ ៣៩៥/១៣ ពព ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៣ ចុះហត្ថ លេខា ដោយលោក [redacted] ផុន មេឃុំព្រៃពូច)។

៣-ឲ្យចុងចម្លើយឈ្មោះ [redacted] សុគន្ធា ជាអ្នកមានអំណាចមេបាលើកូន ឈ្មោះ [redacted] គុជរាជសិទ្ធ ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត ២២-០១-២០១១ គិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ។



Scanned with CamScanner

៩-ឱ្យដើមចោទឈ្មោះ [redacted] សំណាង បង់សោហ៊ុយ ចិញ្ចឹមកូន ជាប្រាក់ ចំនួន ៣០០ ០០០ (បីសែន) រៀលក្នុងមួយខែ ទៅចុងចម្លើយឈ្មោះ [redacted] សុគន្ធា។

៥-ទុកសិទ្ធិឲ្យឪពុកឈ្មោះ [redacted] សំណាង សួរសុខទុក្ខកូន នៅរៀងរាល់ថ្ងៃ សៅរ៍ និង ថ្ងៃ អាទិត្យ ចាប់ពីវេលាម៉ោង ៨ព្រឹក ដល់ម៉ោង ៦ល្ងាច ។

៦-ក្នុងករណីឪពុកឈ្មោះ [redacted] សំណាង ចង់យកកូនទៅលេង ត្រូវមានការឯកភាពជាមួយ ឈ្មោះ [redacted] សុគន្ធា និង កូន ដោយកំណត់ពេលវេលា និង ទីកន្លែង (ក្នុងការប្រគល់ និង ទទួលត្រឡប់មកវិញ)។

៧-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះទាញហេតុផលផ្ទាល់មាត់ នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២០ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០២០ ចំពោះមុខដើមចោទ និង ចំពោះមុខចុងចម្លើយ ។

ទុកសិទ្ធិឲ្យគូភាគីប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ថ្ងៃអង្គារ ១៥ កើត ...ខែ ចេត្រ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

កណ្ដាល,ថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០២០

**ចៅក្រម**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
កណ្ដាល,ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២០
ក្រឡាបញ្ជី

[redacted]



Scanned with CamScanner